**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣៦០ ប្រក. កសក

## ប្រកាស

## ស្ដីពី

## ការគ្រប់គ្រងនិងការដាក់ឲ្យប្រើប្រាស់ស្លាកលេខសម្គាល់សត្វចតុប្បាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/ រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែ វិច្ឆិកា ឆ្នាំ២០០៨ ស្ដីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្មឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្ដីពីការត្រួតពិនិត្យអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ
- បានឃើញអនុក្រឹត្យលេខ១០៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០៧ ស្ដីពីការគ្រប់គ្រងសត្តឃាតដ្ឋាន ការត្រួតពិនិត្យអនាម័យសត្វ សាច់និងផលិតផលសត្វ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១

វិយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
200 Preah Norodom Blvd, Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129 Fax : (855) 23 217 320

## សម្រេច

**ប្រការ១ :~**

ប្រកាសនេះមានគោលបំណងដាក់ឲ្យប្រើប្រាស់ស្លាកលេខសម្គាល់សត្វគោ ក្របី ជ្រូក និងសត្វចតុប្បាទដទៃទៀតដែលធ្វើអាជីវកម្មក្នុងប្រទេស នាំចូល នាំចេញ និងនាំឆ្លងកាត់ដើម្បីតាមដានប្រភពសត្វ គ្រប់គ្រងចរាចរណ៍សត្វ បង្ការ និងទប់ស្កាត់ជំងឺឆ្លងសត្វដែលបង្កហានិភ័យដល់សុខភាពសត្វ សុខភាពមនុស្ស និងផលិតកម្មសត្វ។

**ប្រការ២ :~**

ស្លាកលេខសម្គាល់សត្វគោ ក្របី ជ្រូកនិងសត្វចតុប្បាទដទៃទៀតត្រូវគ្រប់គ្រងដោយនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល។

**ប្រការ៣ :~**

ស្លាកលេខសម្គាល់សត្វធ្វើពីផ្លាស្ទិក មានបួនពណ៌សម្រាប់សម្គាល់ប្រភេទអាជីវកម្មសត្វ អក្សរសម្រាប់សម្គាល់ប្រភេទសត្វ ហើយស្លាកលេខនីមួយៗមានលេខកូដចំនួន១០ខ្ទង់ ដូចខាងក្រោមៈ

- ពណ៌ខៀវសម្រាប់សម្គាល់សត្វធ្វើអាជីវកម្មក្នុងប្រទេស
- ពណ៌ក្រហមសម្រាប់សម្គាល់សត្វនាំចូល
- ពណ៌លឿងសម្រាប់សម្គាល់សត្វនាំចេញ
- ពណ៌បៃតងសម្រាប់សម្គាល់សត្វនាំឆ្លងកាត់
- អក្សរ C សម្រាប់សម្គាល់សត្វគោ
- អក្សរ B សម្រាប់សម្គាល់សត្វក្របី
- អក្សរ S សម្រាប់សម្គាល់សត្វជ្រូក
- អក្សរ A សម្រាប់សម្គាល់សត្វចតុប្បាទដទៃទៀត។

**ប្រការ៤ :~**

ប្រភេទនិងទម្រង់ស្លាកលេខសម្គាល់សត្វគោ ក្របី ជ្រូកនិងសត្វចតុប្បាទដទៃទៀតត្រូវបានកំណត់ ក្នុងឧបសម្ព័ន្ធ១ ២ ៣ និង៤ នៃប្រកាសនេះ។

**ប្រការ៥ :~**

រូបវន្តបុគ្គលឬនីតិបុគ្គលដែលធ្វើអាជីវកម្មក្នុងប្រទេស នាំចូល នាំចេញ និងនាំឆ្លងកាត់សត្វគោ ក្របី ជ្រូក និងសត្វចតុប្បាទដទៃទៀតតម្រូវឲ្យមានស្លាកលេខសម្គាល់ពីអង្គភាពផលិតកម្មនិងបសុព្យាបាល មានសមត្ថកិច្ច។

**ប្រការ៦ :~**

មន្ត្រីផលិតកម្មនិងបសុព្យាបាលមានសមត្ថកិច្ចត្រូវបំពាក់ស្លាកលេខសម្គាល់សត្វក្នុងករណីពិនិត្យតាមបច្ចេកទេសឃើញថាសត្វមានសុខភាពល្អនិងចេញពីប្រភពដែលគ្មានជំងឺឆ្លងរាលដាល។

សិទ្ធិនិងការទទួលខុសត្រូវលើការផ្តល់និងការបំពាក់ស្លាកលេខលើសត្វរបស់មន្ត្រីនិងអង្គភាពផលិតកម្មនិងបសុព្យាបាល មានសមត្ថកិច្ច ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

២

**ប្រការ៧ .-**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត និង ប្រធានការិយាល័យផលិតកម្មនិងបសុព្យាបាលរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ០២ ខែកក្កដា ឆ្នាំ ២០១២

**រដ្ឋមន្ត្រី**

ចាន់ សារុន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- គ្រប់សាលារាជធានី ខេត្ត
- ដូចប្រការ៧
- ឯកសារ កាលប្បវត្តិ

៣

ឧបសម្ព័ន្ធ ១ ភ្ជាប់ប្រកាសលេខ...៣២០.......ប្រក.ក.ស.ក
ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ ២០១២.

## ស្លាកលេខសម្គាល់គោ សម្រាប់ធ្វើអាជីវកម្មក្នុងប្រទេស នាំចូល នាំចេញ និងនាំឆ្លងកាត់




គោធ្វើអាជីវកម្មក្នុងប្រទេស



គោនាំចូល




គោនាំចេញ




គោនាំឆ្លងកាត់

ឧបសម្ព័ន្ធ ២ ភ្ជាប់ប្រកាសលេខ.៣៦០........ប្រក.ក.ស.ក
ចុះថ្ងៃទី ០២ ខែកក្កដា ឆ្នាំ ២០១២

## ស្លាកលេខសម្គាល់ក្របី សម្រាប់ធ្វើអាជីវកម្មក្នុងប្រទេស នាំចូល នាំចេញ និងនាំឆ្លងកាត់




ក្របីធ្វើអាជីវកម្មក្នុងប្រទេស



ក្របីនាំចូល

B.0000000001

ក្របីនាំចេញ



ក្របីនាំឆ្លងកាត់

ឧបសម្ព័ន្ធ ៣ ភ្ជាប់ប្រកាសលេខ...៣៦០.........ប្រក.ក.ស.ក
ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០១២

## ស្លាកលេខសម្គាល់ជ្រូក សម្រាប់ធ្វើអាជីវកម្មក្នុងប្រទេស នាំចូល នាំចេញ និងនាំឆ្លងកាត់




ជ្រូកធ្វើអាជីវកម្មក្នុងប្រទេស



ជ្រូកនាំចូល




ជ្រូកនាំចេញ




ជ្រូកនាំឆ្លងកាត់

ឧបសម្ព័ន្ធ ៤ ភ្ជាប់ប្រកាសលេខ...៣៦០.......ប្រក.ក.ស.ក
ចុះថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ ២០១២.

## ស្លាកលេខសម្គាល់សត្វដទៃទៀត សម្រាប់ធ្វើអាជីវកម្មក្នុងប្រទេស នាំចូល នាំចេញ និងនាំឆ្លងកាត់




ចៀមនិងពពែធ្វើអាជីវកម្មក្នុងប្រទេស



ប្រភេទសត្វដទៃទៀត




ប្រភេទសត្វដទៃទៀត



ប្រភេទសត្វដទៃទៀត